ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | អភិរក្ស អភិវឌ្ឍន៍ធនធាន ជលផលភូមិកំពង់បាស្រូវ |
| ភូមិ | : | កំពង់បាស្រូវ |
| ឃុំ | : | ជលសារ |
| ស្រុក | : | ជលគីរី |
| ខេត្ត | : | កំពង់ឆ្នាំង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : អភិរក្ស អភិវឌ្ឍន៍ធនធាន ជលផលភូមិកំពង់បាស្រូវ

ភូមិ : កំពង់បាស្រូវ

ឃុំ : ជលសារ

ស្រុក : ជលគិរី

ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **អភិរក្ស អភិវឌ្ឍន៏ធនធានជលផលភូមិកំពង់បាស្រូវ** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៤** ខែ **កក្កដា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **អភិរក្ស អភិវឌ្ឍន៏ធនធានជលផលភូមិកំពង់បាស្រូវ** មានទីតាំងស្ថិតនៅក្នុងភូមិ **កំពង់បាស្រូវ** ឃុំ **ជលសារ** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **៧៤០** នាក់ ស្រីចំនួន **៣៨០** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន ០**២** នាក់។ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន **៥៦០** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន : ដាំកូនឈើ , រៀបចំកន្លែងអភិរក្ស ( បឹងឆកឫស្សី), កសាងរោងបុណ្យបាន ៤ , ទិញមេក្រូបាន ៣គ្រឿង, ទិញម៉ាស៊ីនភ្លើងបាន ១ គ្រឿង ទិញម៉ាស៊ីនកាណូតបាឡា ១ គ្រឿង, សង់ស្ពានឈើផ្លូវផ្សារបាន ១, បដិភាគក្នុងការកសាងស្ពានយាយទាល់ ២.៧០០.០០០១៛០០, ជួយអាហាររូបបថមសំរាប់សិស្សចំនួន ៦០០.០០០៛០០, បង់អង្គុយដាក់នៅសាលារៀន ១០ ជួយជួសជុលសាលារៀនអស់ថវិកាចំនួន ១.៣៤០.០០០៛០០, បដិភាគក្នុងការកសាងផ្លូវសហគមន៍នេសាទព្រែកទ្រព្យទៅសហគមន៍នេសាទកោះធំចំនួន ២.០០០.០០០៛០០, ជួសជុលទំនប់ករបឹងខ្សាច់, បង្កើតក្រុមសន្សំបានចំនួន១៦ក្រុម បង្កើតធនាគារស្រូវបាន ១ ក្រុម (១.០០០.០០០៛០០), បង្កើតក្រុមជួយខ្លួនឯងបានចំនួន ១ ក្រុម ( ថវិកា ២០០ $ ឧបត្ថម្ភដោយអង្គការ ស៊ីស៊ីឌី), ធ្វើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ, ចុះបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ, ធ្វើផែនទី, ធ្វើមហាសន្និបាត, ចុះកិច្ចប្រមព្រៀង។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **២៧៩១** នាក់ ប្រុស នាក់ **១.៣៦២** ស្រី **១៤២៩** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **២៧៩១** នាក់ ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាមចំនួន **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៩៩ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៤ នាក់ ស្រី ០នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៧ នាក់ ស្រី ៦ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ១២ នាក់ ស្រី ៦ នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៧ នាក់ ស្រី ៦ នាក់

- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%** ។ ក្រៅពីនេះមានអ្នកកាន់សាសនា អ៊ិស្លាម ប្រមាណ **គ្មាន** សាសនាកាតូលិកប្រមាណ **គ្មាន** ។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **១០** នាក់ ស្រី **៥** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **៦២០** នាក់ ស្រី **៤០៥** នាក់ កំរិតមធ្យមសិក្សាចំនួន **១១០** នាក់ ស្រី **៥៨** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **គ្មាន** នាក់ ស្រី **គ្មាន** នាក់ ។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន:

- ធ្វើនេសាទចំនួន ៥៥៩ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ៥៣៣ គ្រួសារ ទំហំ ១១២១ ហិកតា
- ធ្វើវារីវប្បកម្មចំនួន ១២ គ្រួសារ ស្រះ ៨ និង បែ ៤
- ដាំបន្លែចំនួន ៨ គ្រួសារ ទំហំ ៦៨០០ម$^{២}$
- ជាងផ្ទះចំនួន ១៥ គ្រួសារ
- ត្បាញកន្ទេលកក់មូល ចំនួន ៨ គ្រួសារ
- លក់ដូរចំនួន ៣៥ គ្រួសារ
- កែច្នៃផលនេសាទចំនួន ៥៥៩ គ្រួសារ
- កម្មករកាតដេរចំនួន ១៤៣ នាក់
- កម្មករលីសែងចំនួន ៣៣ នាក់
- រត់ទូកដរចំនួន ៧ នាក់
- ជាងទូកចំនួន ១០ នាក់
- បញ្ចូលអាគុយចំនួន ៤ គ្រួសារ
- ម៉ាស៊ីនបោកស្រូវចំនួន ៣ គ្រួសារ
- ដាំពោតចំនួន ២០ គ្រួសារទំហំ ២,៧០ ហិកតា
- ស៊ីឈ្នួលគេចំនួន ៣ នាក់
- ដាំសណ្តែក ១២ គ្រួសារទំហំ ២,៥ ហិកតា

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

## ក. ទីតាំង

កន្លែងនេសាទសហគមន៍ **អភិរក្ស អភិវឌ្ឍន៍ធនធានជលផលភូមិកំពង់បាស្រូវ** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ **១៥** ដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **អភិរក្ស អភិវឌ្ឍន៍ធនធានជលផលភូមិកំពង់បាស្រូវ** មានទំហំ **២.៦៨៩** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **សហគមន៍នេសាទព្រែកទ្រព្យ**
- ខាងត្បូងទល់នឹង **សហគមន៍នេសាទបត់ត្រង់**
- ខាងកើតទល់នឹង **ចំណុចចុងឆ្កោព្រួ**
- ខាងលិចទល់នឹង **សហគមន៍នេសាទគរជ្រុំ**

## ៩. ផែននេសាទ

កន្លែងនេសាទសហគមន៍ **អភិរក្ស អភិវឌ្ឍន៍ធនធានជលផលភូមិកំពង់បាស្រូវ** មានបឹងចំនួន **១៣** ព្រែកចំនួន **២** ទំនាបចំនួន **៣** មេទឹកចំនួន **១៤** និងព្រៃលិចទឹកចំនួន **៣** កន្លែង។

| | | |
|---|---|---|
| - បឹងធំ | ទំហំ ៤៣០០ម x ២៥០ម | នេសាទពេញមួយឆ្នាំ |
| - បឹងឆកឫស្សី | ទំហំ ៣០០០ម x ៥០ម | កន្លែងការពារ ( អភិរក្ស) |
| - បឹងគោស្លាប់ | ទំហំ ១២៥០ម x ៤៧ម | នេសាទពេញមួយឆ្នាំ |
| - បឹងចាក្រុងក្រៅ | ទំហំ ៧.០០០ម$^២$ | នេសាទពីខែ កុម្ភៈ ដល់ខែ មេសា |
| - បឹងចាក្រុងក្នុង | ទំហំ ៨.០០០ម$^២$ | នេសាទពីខែ កុម្ភៈ ដល់ខែ មេសា |
| - បឹងទំនាបតាសន | ទំហំ ២០០ម x ៧០ម | នេសាទពខែ មករា ដល់ខែ មេសា |
| - បឹងតាឆាក | ទំហំ ៤០០ម x ៤០ម | |
| - បឹងរនាលភេ | ទំហំ ៣០០ម x ៦០ម | |
| - បឹងប្រគៀបធំ | ទំហំ ៥០០ម x ៥០ម | |
| - បឹងរូង | ទំហំ ២៧០ម x ៦០ម | |
| - បឹងស្វាស្លាប់ | ទំហំ ៥៨០ម x ៤៥ម | |
| - បឹងផ្សោត | ទំហំ ១០០ម x ១០០ម | |
| - បឹងប្រគៀបតូច | ទំហំ ១៥០ម x ៦០ម | |
| - ព្រែកគោស្លាប់ | ទំហំ ១.២០០ម x ១៥ម | នេសាទពខែ មករា ដល់ខែ មេសា |
| - ព្រែកកំពង់បាស្រូវ | ទំហំ ៨០០ម x ៣០ម | នេសាទពខែ មករា ដល់ខែ មេសា |
| - ទំនាបយាយទាល់ | ទំហំ ៣០០ម x ៤០ម | នេសាទពខែ មករា ដល់ខែ កុម្ភៈ |
| - ទំនាបតាឌិត | ទំហំ ៣០០ម x ៥ម | នេសាទពខែ សីហា ដល់ខែ កញ្ញា |
| - ទំនាបផ្លូវផ្សារ | ទំហំ ១៥០ម x ១០ម | នេសាទពខែ សីហា ដល់ខែ កញ្ញា |
| - មេទឹកទំនប់យាយម៉ុច | ទំហំ ៧៥.០០០ម$^២$ | ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង) |

- មេទឹកទំនប់ព្រៃខ្មោច ទំហំ ១៥៦.២០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកក្បៀនដារ ទំហំ ៥៨៥.០០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកចង្អូត ទំហំ ៣៣៣.៩០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកប្រាំងថ្មី ទំហំ ៥៩៨.០០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកទំនប់ច្រកែងខ្ពស់ ទំហំ ១៤៩.៤០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកត្រពោធិ៍ ទំហំ ២.២៦០.០០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកកំពីងពួយ ទំហំ ១៣៩.៥០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកទំនប់ស្មោ ទំហំ ១៣៧.៥០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកផ្សោត ទំហំ ៣១៥.០០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកកាត់ក្បាល ទំហំ ១.០៨៩.០០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកននោង ទំហំ ៣១៥.០០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹកជំទាវមាស ទំហំ ៣៩៧.៥០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- មេទឹករាំងដួច ទំហំ ៣៩៧.២០០ម$^{២}$ ពុំធ្វើនេសាទ ( យកទឹកដាក់ប្រាំង)
- ព្រៃលិចទឹកមានទំហំសរុប ទំហំ ១៤,៧៥ ហិកតា
- ព្រៃលិចទឹកឆកឫស្សី ទំហំ ៩ ហិកតា
- ព្រៃលិចទឹកបឹងធំ ទំហំ ២ ហិកតា
- ព្រៃលិចទឹកគោស្លាប់ ទំហំ ៣,៧៥ ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប **២.៦៨៩** ហិកតា ។

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឆកឫស្ស ទំហំ ២១ ហិកតា ( បណ្តោយ ៣.០០០ម និង ទទឹង ៧០ម)
- បឹងធំ ទំហំ ១០,៥ហិកតា ( បណ្តោយ ៧០០ម និង ទទឹង ១៥០ម)

**ឃ. ធនធានផលផល**

- ប្រភេទត្រីដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានធ្វើការបែងចែកជាបីប្រភេទ :

១- ប្រភេទត្រីដែលមានការកើនឡើង : ត្រីរៀល លិញ ឆ្លាំង ចង្វា ចង្កែង ក្លាំងហាយ ក្រឡង់ ក្រុស ស្រកាក្តាម កាហែ ជន្ទាស់ភ្លក់ ស្លឹកឫស្សី ។

២- ប្រភេទត្រីដែលមានការថយចុះ : ត្រីឆ្តោ កន្ទ្រប់ ស្លាត គ្រុំ ក្រម៉ម ឆ្អិន ព្រួល ឆ្ពោក ក្អែក ក្រាយ ត្រនេល គល់រាំង អណ្តាតឆ្កែ កញ្ចុះ កន្ទ្រង់ប្រេង ខ្ញឹង ឆ្លូញ ជន្ទួញមាន់ កំភ្លាវ កែស ផ្ទោង ត្រីចេក ខ្នាន់ បណ្តូលអំពៅ កញ្ជ្រូក កន្ធរ កញ្ជន កញ្ជោក់ស្លា និងអន្ទង់ ។

៣- ប្រភេទត្រីដែលពុំមានកើន ឬថយ : ត្រីរស់ អណ្តែង ក្រាញ់ ប្រា ពោធិ៍ ដីរ ប្រលូង។

- ប្រភេទវារីសត្វ : ក្តាម កំពិស អណ្តើក ខ្យង ពស់ ហ៊ីង គីង្គក់ កន្ធាយ អន្ទង់។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ : ដើមរាំង ច្រកែង ត្រសេក ត្រស់ ផ្តៅល គួរ ភ្នំភ្លើង បបួយ បបោស ទន្លា ថ្លើមអណ្តើក កប្បាស់ព្រៃ រញ្ជៀវ ទានព្រៃ សាច់ប៊ូវ បន្ទាឃ្លេ អញ្ចាញ បន្លាស្អិត ភ្អែកព្រាប ខ្នាយមាន់ អាវក្រពើ ឆ្អឹងពស់ ទ្រនុំអែអូត ក្រ ធ្នោត សណ្តាន់ តាសែន ស្តី ថ្ងូវ វល្លិព្រេង ដូងព្រះ វល្លិត្រី វល្លិទឹកដោះ ញរ ត្រែង ប៉ធិញញី ប៉ធិញឈ្មោល សំរ៉ក អំពៅព្រៃ ឫស្សី កំប្លោក ចក ព្រលិត ត្រកួន ជីប្លង កំពឹងពួយ កន្ទាំងហៃ ស្រមៃ ស្មៅប្រកអណ្តើក រពាក់ទឹក ជន្ទល់ភ្នំ ស្តន់ ស្លាបចង្វារ ក្រចាប់ ស្បង់កាច់ ស្មោរទឹក ស្មោទឹក សារាយ ព្រីង ម៉ូយ អំពិលបារាំង ននោងក្អែក (ននោងព្រៃ) ត្រជិត តាអើក សង្កែ បន្ទាយូន ខ្ទុម ដង្កៀបក្តាម ទ្រាលទឹក (ក្តតា) ផ្តៅ ស្លាបទា ស្តៃព្រៃ ម្ទេសទឹក ម្រះព្រៃ អណ្តាតត្រកួត អណ្តាតគោ និងវល្លិជុយ។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៧៤០ នាក់ ស្រី ៣៨០ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៥៨០នាក់ ស្រី ៣៧០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៥០០ នាក់ ស្រី ៥០ នាក់

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៨០ម | (២៥ x ១៥០ន) =៣០០ | ចំនួន=២៤០០០ម.ជ=១.៥ម ក្រលា=២-៦សម | កញ្ញា - ធ្នូ |
| សន្ទូចរនង | ផ្លែ | (៣០០ផ្លែ x ៣៥ន) | ចំនួន=១០៥០០ផ្លែ.លេខ=១១- | សីហា - ធ្នូ |
| បង្កៃ | ផ្លែ | (២០០ផ្លែ x ៨ន) | ១៦០០ ផ្លែ | មករា - មីនា |
| លប | គ្រឿង | (១៥ល x ៥០ន) | ចំនួន=៧៥០.មុខកាត់=០៦សម កំពស់=១.៥ម | កញ្ញា - មេសា |
| សៃយ៉ឺនកំពិស | គ្រឿង | (២៥០ x ១៦ន) | ៤០០០ សៃយ៉ឺន | កញ្ញា - មករា |
| លាន់ | គ្រឿង | (៤០ល x ១៥ន) | ៦០០ លាន់ | កញ្ញា - មករា |
| ថ្នង | គ្រឿង | (១៥ x ២៥ន) | ២៥ ថ្នង | សីហា - កញ្ញា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកត្នោត | ១៥ គ្រឿង | ១០០ គក្រ | |
| ទូកឈើ | ៣៥០ គ្រឿង | ៣០០ គក្រ | |
| កាណូត | ៣៥០ គ្រឿង | ៥០០គក្រ — ១០០០គក្រ | ៣.៥សេះ - ១២សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ១ដៃ=៨០ម | (២៥ x ៥០ន)<br>=១០០ | ចំនួន=៨០០០ម.ជ=១.៥ម<br>ក្រលា=២-៦សម |
| សន្ទូចរនង | ផ្លែ | (៣០០ផ្លែ x ១៥ន) | ចំនួន=៤៥០០ផ្លែ.លេខ=១១- |
| បង្កៃ | ផ្លែ | (២០០ផ្លែ x ៣ន) | ៦០០ ផ្លែ |
| លប | គ្រឿង | (១៥០ x ១០ន) | ចំនួន=១៥០.មុខកាត់=០៦សម<br>កំពស់=១.៥ម |
| សៃយ៉ឺនកំពិស | គ្រឿង | (១៥០ x ៦ន) | ៩០០ សៃយ៉ឺន |
| លាន់ | គ្រឿង | (២០០ x ៥ន) | ១០០ លាន់ |
| ថ្នង | គ្រឿង | (១៥ x ៨ន) | ៨ ថ្នង |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកត្នោត | ២ គ្រឿង | ៨០ គក្រ | |
| ទូកចែវ | ២០ គ្រឿង | ៣០០ គក្រ-៥០០គក្រ | |
| ទូកម៉ាស៊ីន | ៥ គ្រឿង | ១០០០គក្រ-៥០០០ | ៣.៥សេះ - ១៨សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ១ដៃ=៨០ម | (២៥ x ៦ន)=១២ | ចំនួន=៩៦០ម.ជ=១.៥មក្រលា=២-៦សម |
| សន្ទូចរនង | ផ្លែ | (៣០០ផ្លែ x ៥ន) | ចំនួន=១៥០០ផ្លែ.លេខ=១១- |
| បង្កៃ | ផ្លែ | (២០០ផ្លែ x ៣ន) | ៦០០ ផ្លែ |
| ប្រយុង | គ្រឿង | (៣៥វង់ x ៣ន) | ចំនួន=៣វង់.ជ=៣.៥សម ក្រលា=២-៦សម.<br>ប្រវែង=៣៥ម/វង់ |
| អង្រុត | គ្រឿង | (១ក្រ x ៤៥ន) | ៤៥ អង្រុត |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកគ្មោត | ៥ គ្រឿង | ១០០ គក្រ | |
| ទូកចែវ | ១០ គ្រឿង | ៣០០ គក្រ-៦០០គក្រ | |
| កាណូត | ៣ គ្រឿង | ១២០០គក្រ -៦០០០គក្រ | ៨សេះ -២២សេះ |

**គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៥៥០០គក្រ | ៨៣០០គក្រ | ១៣៨០០គក្រ |
| ក្តាម ខ្យង | ៨០គក្រ | ១៦០គក្រ | ២៤០គក្រ |
| អន្ទង់ | ៦០គក្រ | ៧០គក្រ | ១៣០គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនវិស័យ

សហគមន៍នេសាទ **អភិរក្ស អភិវឌ្ឍន៍ធនធានជលផលភូមិកំពង់បាស្រូវ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬ កាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទៈ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងធំ | ពេញមួយឆ្នាំ | - មង<br>- សន្ទូចរនង<br>- បង្កៃ<br>- លប<br>- សំណាញ់ | - ២៤០០០ ម<br>- ១២០០០ ផ្លែ<br>- ១០០០ បង្កៃ<br>- ២០០ គ្រឿង<br>- ៣០ វង់ | - ១៥០ នាក់<br>- ៣០នាក់<br>- ១០នាក់<br>- ២០ នាក់<br>- ៣០នាក់ | ក្រលា=២-៦សម<br>លេខ=១១-១៣<br>កំពស់=១.៥ម<br>មុខកាត់=៦០សម |
| បឹងគោស្លាប់ | ពេញមួយឆ្នាំ | - មង<br>- សន្ទូចរនង<br>- បង្កៃ<br>- លប<br>- សំណាញ់<br>- អង្រុត<br>- លាន់ | - ៤៥០០ម<br>- ៧០០០ ផ្លែ<br>- ៤០០ ផ្លែ<br>- ៤០ គ្រឿង<br>- ១៥ វង់<br>- ១៣ គ្រឿង<br>- ២១០ គ្រឿង | - ១២ នាក់<br>- ០៥ នាក់<br>- ០២ នាក់<br>- ០៨ នាក់<br>- ១៥ នាក់<br>- ១៣ នាក់<br>- ០៧ នាក់ | ក្រលា=២-៦សម<br>លេខ=១១-១៣<br>កំពស់=១.៥ម<br>មុខកាត់=៦០សម |
| ព្រៃកំពង់បាស្រូវ | វិច្ឆិកា-កក្កដា | - មង<br>- សន្ទូចរនង<br>- បង្កៃ<br>- លប | - ២០០០ម<br>- ៨០០ ផ្លែ<br>- ២០០ បង្កៃ<br>- ១០ គ្រឿង | - ១០ នាក់<br>- ០៤ នាក់<br>- ០២ នាក់<br>- ០២ នាក់ | ក្រលា=៣-៦សម<br>លេខ=១១-១៣<br>កំពស់=១.៥ម<br>មុខកាត់=៦០សម |
| ព្រៃគោស្លាប់ | វិច្ឆិកា-កក្កដា | - មង<br>- សន្ទូចរនង<br>- បង្កៃ<br>- លប | - ៨០០ម<br>- ៩០០ ផ្លែ<br>- ១៥០ បង្កៃ<br>- ៣០ គ្រឿង | - ០៣នាក់<br>- ០៣ នាក់<br>- ០២ នាក់<br>- ០៦ នាក់ | ក្រលា=២-៦សម<br>លេខ=១១-១៣<br>កំពស់=១.៥ម<br>មុខកាត់=៦០សម |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្តារមាត់ព្រែក ករបឹងធំ | ៣,០៩ ហត | - បណ្តោយ ២៥០ម<br>- ទទឹង ១៥០ ម<br>- ជំរៅ ២ ម | ប្រើគ្រឿង ចក្រ | ៤/០៩ | ៧/២០១០ | |
| ស្តារព្រែក គោស្លាប់ | ២ ហត | - បណ្តោយ ១២៦០ម<br>- ទទឹង ១៥ ម<br>- ជំរៅ ២ ម | ប្រើគ្រឿង ចក្រ | ០២/០៩ | ៧/២០១០ | |
| ធ្វើទ្វារទឹក ករបឹងធំ | ១៨ ម | - បណ្តោយ ៣ម<br>- ទទឹង ៦ ម<br>- កំពស់ ២ ម | កំលាំងពល កម្មគណៈ កម្មការ | ៣/០៩ | ៧/២០១០ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងធំ | - បណ្តោយ ៧០០ម<br>- ទទឹង ១៥០ ម | អភិរក្សត្រីមេពូជនិងជីវចំរុះ | - បោះបង្គោល<br>- ដាក់ជំរកសិប្បនិម្មិត<br>- ព័ទ្ធខ្សែលួស<br>- សង់ប៉ុស្តិ៍យាម<br>- ដាក់ស្លាកសញ្ញា<br>- ថែរក្សា ល្បាត. | ០១/៣/០៩ | ៣១/៧/០៩ | |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១- បឹង និងព្រៃកគោស្លាប់ | ៣,៧៨ ហត | ការពារប្រភេទព្រៃលិចទឹក | - ដាក់ស្លាកសញ្ញា<br>- បោះបង្គោល<br>- ល្បាត<br>- ប្រជុំផ្សព្វផ្សាយ | ០១/០១/០៩ | ១២/២០១០ | |
| ២- បឹងឆកបូស៊ី | ២៤.៣៦ហត | ការពារប្រភេទព្រៃលិចទឹក | - ដាក់ស្លាកសញ្ញា<br>- បោះបង្គោល<br>- ល្បាត<br>- ប្រជុំផ្សព្វផ្សាយ | ០១/០១/០៩ | ១២/២០១០ | |
| ៣- បឹងធំ | ៣ ហត | ការពារប្រភេទព្រៃលិចទឹក | - ដាក់ស្លាកសញ្ញា<br>- បោះបង្គោល<br>- ល្បាត<br>- ប្រជុំផ្សព្វផ្សាយ | ០១/០១/០៩ | ១២/២០១០ | |
| ចំណុចចាអោកមាត់បឹងធំ | ១ ហត | ដាំកូនឈើប្រភេទព្រៃលិចទឹក | - បណ្តុះកូនឈើ<br>- ប្រមូលទិញពីប្រជាពលរដ្ឋ<br>- ធ្វើពិធីដាំ | ០១/០១/០៩ | /៧/២០១០ | |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

-ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| បៃ (៤ម x ១២ម) | ០៥ | ត្រីប្រា/ពោធិ៍ | ១៥.០០០កូន / ៥បៃ | ០១/០១/០៩ | ៧/២០១០ |
| បៃ (៤ម x ៦ម) | ០៥ | ត្រីឆ្ពិន | ៥០០០កូន / ៥បៃ | ០១/០៣/០៩ | ៣/២០១០ |

| | | | | | |
|---|---|---|---|---|---|
| បៃ (៤ម x ៨ម) | ០៥ | កាហែ | ៧៥០០កូន / ៥បៃ | ០១/៤/០៩ | ៦/២០១០ |
| បៃ (៤ម x ៦ម) | ០៥ | ត្រីច្រឡឹង | ៧៥០០កូន / ៥បៃ | ០១/៦/០៩ | ២/២០១០ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលតាមផ្ទះ | ០១/០១/០៩ | ៣០/៦/០៩ | ៣៧០.០០០រ | |
| ភាគទានប្រចាំឆ្នាំ | ប្រមូលតាមផ្ទះ | ០១/០១/០៩ | ៣០/៦/០៩ | ៧៤០.០០០រ | |
| ភាគទានប្រចាំឆ្នាំ | មកបង់នៅស្នាក់ការ | ០១/០១/០៩ | ៣០/៦/០៩ | ៧៤០.០០០រ | |
| ភាគទានប្រចាំឆ្នាំ | មកបង់នៅស្នាក់ការ | ០១/០១/០១០ | ៣០/៦/០១០ | ៧៤០.០០០រ | |
| ចំណូលពីការធ្វើនេសាទ | គណៈកម្មការសហគមន៍ និងគណៈកម្មការសហព័ន្ធ បង្កើតក្រុមធ្វើនេសាទ | ០១/១១/០៩ | ៣០/៧/០៩ | ៥ លានរៀល | |
| ចំណូលពីការធ្វើនេសាទ | គណៈកម្មការសហគមន៍ និងគណៈកម្មការសហព័ន្ធ បង្កើតក្រុមធ្វើនេសាទ | ០១/១១/០៩ | ៣០/៧/០៩ | ៥ លានរៀល | |
| ចំណូលពីការធ្វើនេសាទ | គណៈកម្មការសហគមន៍ និងគណៈកម្មការសហព័ន្ធ បង្កើតក្រុមធ្វើនេសាទ | ០១/១១/០៩ | ៣០/៧/០១០ | ៥ លានរៀល | |

## គ-៧ ផែនការបង្កើតមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | ចំនួន | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ជីកស្រះចិញ្ចឹមត្រី | ១២គ្រួសារ | ប្រជុំផ្សព្វផ្សាយ ជ្រើសរើសទីកន្លែងសមស្រប.កំលាំងពលកម្ម. គ្រឿងចក្រ | មិនា ២០០៩ | មិថុនា ២០១០ | ៧៥០០ ដុល្លា |
| បង្គន់អនាម័យ | ២០ គ្រួសារ | សំណើសុំរៀបចំធ្វើប្រជុំប្រមូលថវិកាបដិភាគ និងរៀបចំឈ្មោះគ្រួសារដែលត្រូវធ្វើ ជួលជាង. | កុម្ភៈ ២០០៩ | កុម្ភៈ ២០១០ | ៣០០០ ដុល្លា |
| ចិញ្ចឹមគោមេ | ៥ គ្រួសារ ១ក្បាល/គ្រ | -ធ្វើទ្រុងបង្រៀនការថែទាំអោយចំណី- រកពូជល្អមកបង្កាត់ និងព្យាបាលពេលមានជំងឺនិងចែក | ឧសភា ២០០៩ | ឧសភា ២០១០ | ១៥០០ |

| | | | | | |
|---|---|---|---|---|---|
| | | ចាយកូនទៅគ្រួសារក្រីក្របន្តទៅទៀត ។ | | | ដុល្លា |
| ចិញ្ចឹមមាន់, ទា, ជ្រូក | ៤០គ្រួសារ ៣ក្បា/គ្រ ឈ្មោល១ក្បា ញី២ក្បាល | - ធ្វើទ្រូងបង្រៀនការថែទាំផ្តល់ចំណី និងព្យាបាលពេលមានជំងឺ និងចែកចាយកូនទៅគ្រួសារក្រីក្របន្តទៅទៀត ។ | មេសា ២០០៩ | មិថុនា ២០១០ | ១៥០០ដុល្លា |

## គ-៤ ផែនការផ្សេងៗទៀត

ផែនការដែលត្រូវធ្វើរយៈពេលបីឆ្នាំមានដូចខាងលើ ជាផែនការមួយដែលធ្វើការអភិវឌ្ឍន៍សហគមន៍នេសាទទាំងមូល ហើយបើពិនិត្យទៅលើ SWOT បានឱ្យដឹងពីកង្វះខាតជាច្រើន និងត្រូវធ្វើការដោះស្រាយចំពោះមុខ ។

ការធ្វើការបង្ហាញតាមរយៈ SWOT

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| - បង្កើតបានក្រុមសន្សំចំនួន ១៥ ក្រុម | - មិនទាន់មានស្នាក់ការសហគមន៍នេសាទ |
| - ក្រុមជួយខ្លួនឯងចំនួន ១ ក្រុម | - ចំណេះដឹងគណៈកម្មការសហគមន៍នេសាទនៅមានកំរិត |
| - បង្កើតបានធនាគារស្រូវចំនួន ១ ក្រុម | - បទល្មើសរបាំងរ៉ាវនៅតែមាន |
| - សាងសង់រោងបុណ្យបានចំនួន ៤ | - ព្រៃលិចទឹកមានការកាប់បំផ្លាញដើម្បីពង្រីកដីស្រែ |
| - ទិញបានម៉ាស៊ីនភ្លើងបានចំនួន ១ គ្រឿង | - ជីវភាពសមាជិកសហគមន៍នេសាទមានការខ្វះខាត |
| - ទិញមេក្រូបានចំនួន ៣ គ្រឿង | - សហគមន៍គ្មានចំណូលដើម្បីធ្វើការអភិវឌ្ឍន៍សហគមន៍ |
| - ចូលរួមធ្វើផ្លូវថ្នល់ | - ខ្វះខាតឧបករណ៍និងសម្ភារៈសំរាប់ប្រើប្រាស់ក្នុងសហគមន៍ |
| - ទិញបង់អង្គុយដាក់សាលារៀនចំនួន ១០ បង់ | - ខ្វះបច្ចេកទេសចិញ្ចឹមសត្វ និងដាំដំណាំ |
| - ចូលរួមជួយជាអាហារូបត្ថម្ភដល់សិស្ស | - ខ្វះពូជសត្វចិញ្ចឹម ( គោ, ក្របី, ជ្រូក, មាន់) |
| - ជយសជុលសាលារៀន | - ខ្វះបង្គន់អនាម័យ |
| - ធ្វើស្ពាន ២ កន្លែង | - បឹង ព្រែក រីងរាក់ |
| - ធ្វើទីប៉ាឆា | - ទំនប់មេទឹក និងទ្វារទឹកបាក់បែក |
| - ដាំកូនឈើ | - កុមារកំព្រាខ្វះការឧបត្ថម្ភ |
| - ទិញម៉ាស៊ីនកាណូតបាឡា | - ខ្វះការទំនាក់ទំនង |
| - ទិញកេះ និងសៀវភៅជួយក្រុមសន្សំ | |

| | |
|---|---|
| - ផ្សព្វផ្សាយការងារសហគំនី<br>- ទទួលបានធុងចំរោះទឹកស្អាតចំនួន ៣៦៤ ធុង | |
| ឱកាស | ការគំរាមកំហែង |
| - កំណែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាល<br>- មានអង្គការ CCD ជួយឧបត្ថម្ភ និងគាំទ្រ<br>- មានការគាំទ្រពីជំនាញជលផល<br>- មានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន<br>- មានការចូលរួមពីប្រជាពលរដ្ឋ<br>- មានការទទួលស្គាល់ពីរដ្ឋាភិបាល | - គណៈកម្មការសហគមន៏នេសាទមានចំណេះដឹងមានកំរិត<br>- គណៈកម្មការសហគមន៏នេសាទ មានការយល់ដឹងពីច្បាប់ស្តីពីជលផល និងអនុក្រិត្យស្តីពីការគ្រប់គ្រងសហគមន៏នេសាទនៅមានកំរិតទាប ។<br>- ពុំមានថវិកាក្នុងការអភិវឌ្ឍន៏សហគមន៏នេសាទ<br>- ពុំសូវមានធនធានមនុស្ស |

ដើម្បីឆ្លើយតបទៅនឹងចំណុចខ្សោយ និងការគំរាមកំហែងដែលបានបង្ហាញនៅក្នុងតារាង SWOT សហគមន៏នេសាទត្រូវធ្វើការដោះស្រាយចំពោះមុខជាបន្ទាន់ដូចជា :

- បង្កើតស្នាក់ការសហគមន៏នេសាទ
- ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៏ ( បើកវគ្គបណ្តុះបណ្តាល)
- បង្កើតមុខរបរបន្ថែមដល់សមាជិកសហគមន៏នេសាទដើម្បីឱ្យពួកគាត់មានជីវភាពធូរធា
- ទិញឧបករណ៍ និង សម្ភារៈសំរាប់ប្រើប្រាស់ក្នុងសហគមន៏
- បង្រៀនបច្ចេកទេសចិញ្ចឹមសត្វ និងដាំដំណាំ
- ផ្តល់ពូជសត្វចិញ្ចឹម ( គោ, ក្របី, ជ្រូក, មាន់)
- ផ្តល់បង្គន់អនាម័យ
- បង្កើតឱ្យមានជាអាហាររូបករណ៏ដល់កុមារកំព្រា
- បណ្តុះបណ្តាលពីជំនាញទំនាក់ទំនង និងរដ្ឋបាល

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៏ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៏នេសាទ ចាស់ទុំ និងសមាជិកសហគមន៏នេសាទដែល មានបទពិសោធន៏ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស

ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កំពង់បាស្រូវ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ . | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | អនុវត្តទៅតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍ | - ពុំមានការប្រើប្រាស់ឧបរណ៍ល្មើសច្បាប់ ។<br>- ប្រជាពលរដ្ឋអនុវត្តបានទាំងអស់គ្នា ។<br>- ផលត្រីកើនឡើង | ៣០០ ដុល្លា | | ០១/០១/០៩ | ៣១/១២/០១០ | |
| ២. ការកែលំអដែននេសាទ | - ស្តារដោយគ្រឿងចក្រ<br>- គណៈកម្មការសហគមន៍ចូលរួមធ្វើដោយផ្ទាល់ ។ | - មានទឹកប្រើប្រាស់គ្រប់<br>- រក្សាត្រីបានគង់វង់<br>- សំបូរជីវចំរុះ | ៦០០០ ដុល្លា | ថវិកាអភិវឌ្ឍន៍ឃុំ | ០១/៣/០៩ | ៣១/១២/០១០ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | - បោះបង្គោល<br>- ដាក់ជំរកសិប្បនិម្មិត<br>- ព័ទ្ធខ្សែលួស<br>- សង់ប៉ុស្តិ៍យាម<br>- ដាក់ស្លាកសញ្ញា<br>- ល្បាត | - ធនធានជលផលមានការកើនឡើង ។<br>- សំបូរត្រីសំរាប់នេសាទ<br>- សហគមន៍មានចំណូល<br>- មានការចូលរួមថែរក្សាទាំងអស់គ្នា ។ | ៧០០០ ដុល្លា | ថវិកាអភិវឌ្ឍន៍ឃុំ | ០១/៣/០៩ | ៣១/៧/០៩ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | - ដាក់ស្លាកសញ្ញា<br>- បោះបង្គោល<br>- ល្បាត<br>- ប្រជុំផ្សព្វផ្សាយ<br>- បណ្តុះកូនឈើ និងដាំ | - ព្រៃលិចទឹកនៅគង់វង់<br>- សហគមន៍ថែរក្សាទាំងអស់គ្នា និងគោរពច្បាប់<br>- ត្រី និងសត្វមានជំរកនិងចំណីគ្រប់គ្រាន់ ។ | ៣០០០ ដុល្លា | ថវិកាអភិវឌ្ឍន៍ឃុំ | ០១/០១/០៩ | ៣១/១២/០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥- ផែនការអភិវឌ្ឍនវារីវប្បកម្ម | - សាង់សង់បែ ២០បែ<br>- ជីកស្រះ<br>- សំអាតបែ និងស្រះ | មានចំណូលបន្ថែមពីការលក់ត្រី និងកាត់បន្ថយការចាប់ពីធម្មជាតិ ។ | ១៦០០ ដុល្លា | ថវិកាអភិវឌ្ឍន៍ឃុំ | ០១/០១/០៩ | ៣១/១២/០១០ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ការបង់ភាគទានប្រចាំឆ្នាំរបស់សមាជិកសហគមន៍ ។<br>- បង្កើតក្រុមធ្វើនេសាទរបស់គណៈកម្មការសហគមន៍ | មានថវិកាដើម្បីធ្វើការអភិវឌ្ឍន៍សហគមន៍នេសាទ។ | ៤៥០០ ដុល្លា | ថវិកាសមាជិកសហគមន៍ និងក្រុមនេសាទ | ០១/០១/០៩ | ៣១/១២/០១០ | |
| ៧- បង្កើតស្នាក់ការ | - ទាក់ទងតាមអង្គការ<br>- ទាក់ទងឃុំ<br>- អំពាវនាវសមាជិក | មានកន្លែងធ្វើការ មានកន្លែងទុកដាក់ឯកសារ មានកន្លែងប្រជុំ។ | ៥០០០ ដុល្លា | - ថវិកាឃុំ<br>- ថវិកាអង្គការ<br>- ថវិកាសហគមន៍ | ០១/០១/០៩ | ៣១/១២/០៩ | |
| ៨- បើកវគ្គបណ្តុះបណ្តាលដល់គណៈកម្មការសហគមន៍ | - ទាក់ទងតាមអង្គការ<br>- ទាក់ទងឃុំ<br>- ទាក់ទងជំនាញជលផល | - គណៈកម្មការធ្វើការដោយរលូន។<br>- មានអភិបាលកិច្ចល្អ | ២០០ | - ថវិកាឃុំ<br>- ថវិកាអង្គការ | ០១/០១/០៩ | ៣១/១២/០១០ | |
| ៩- បង្កើតឱ្យមានជាអាហាររូបករណ៍ដល់កុមារកំព្រា | - ទាក់ទងតាមអង្គការ<br>- ទាក់ទងឃុំ<br>- ទាក់ទងជំនាញជលផល<br>- ទំនាក់ទំនងសប្បុរសជន | - កុមារកំព្រាបានបន្តនូវចំណេះដឹងរបស់ខ្លួន។<br>- សមាជិកសហគមន៍យល់ច្បាស់ពីការងារសហគំន៍នេសាទ | ៣០០០ ដុល្លា | - ថវិកាឃុំ<br>- ថវិកាអង្គការ | ០១/០១/០៩ | ៣១/១២/០១០ | |
| ១០- ផ្តល់បង្គន់អនាម័យ | - ប្រជុំពិភាក្សារួមក្នុងភូមិ<br>- ជ្រើសរើសជាង<br>- ដំណើរការសាងសង់ | - ប្រជាពលរដ្ឋមានសុខភាពល្អ និងបរិស្ថានរស់នៅស្អាត | ១៨០០ ដុល្លា | - ថវិកាឃុំ<br>- ថវិកាអង្គការ<br>- ថវិកាសហគមន៍ | ០១/០១/០៩ | ៣១/១២/០១០ | |
| ១១- ផ្តល់ពូជសត្វ | - ប្រជុំពិភាក្សា និងបង្កើត | - មានចំណូលពីរបរ | ១២០០ ដុល្លា | - ថវិកាឃុំ | ០១/០១/០៩ | ៣១/១២/០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ចិញ្ចឹម ( គោ. ក្របី.<br>ជ្រូក. មាន់ ) | ក្រុម ។<br>- តាមដាន និងត្រួតពិនិត្យ | បន្ថែម ។<br>- កាត់បន្ថយការប្រើ<br>ប្រាស់ធនធានជលផល | | | | | |
| ១២- បង្រៀនបច្ចេក<br>ទេសចិញ្ចឹមសត្វ និង<br>ដាំដំណាំ | - ប្រជំពិភាក្សា និងជ្រើស<br>រើសវគ្គ ព្រមទាំងដំណាំ<br>- តាមដាន និងវាយតម្លៃ | ការចិញ្ចឹមសត្វ និងដាំ<br>ដំណាំទទួលបាលទិន្នផល<br>ខ្ពស់ | ១០០០ ដុល្លា | - ថវិកាឃុំ | ០១/០១/០៩ | ៣១/១២/០១០ | |
| ១៣- ទិញឧបករណ៍<br>និង សម្ភារៈសំរាប់ប្រើ<br>ប្រាស់ក្នុងសហគមន៏ | - មានការជ្រើសរើសតម្លៃ<br>- មានការត្រួតពិនិត្យ<br>- មានការចូលរួមពីអាជ្ញាធរ | - សហគមន៏មានដំណើរ<br>ការល្អ ។<br>- ទប់ស្កាត់បទល្មើសទាន់<br>ពេលវេលា ។ | ១៣០០ ដុល្លា | - ថវិកាឃុំ | ០១/០១/០៩ | ៣១/១២/០១០ | |

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០០៨ | | | | | | | | | | | | ២០០៩ | | | ២០១០ | | |
| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ធ្នូ |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រង ព្រៃលិចទឹក | | | | | | | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍ នីវារីវប្បកម្ម | | | | | | | | | | | | | | | | | | |
| ៦. ផែនការរកប្រាក់ ចំណូលសហគមន៍ | | | | | | | | | | | | | | | | | | |
| ៧. បង្កើតស្នាក់ការ | | | | | | | | | | | | | | | | | | |
| ៨.បើកវគ្គបណ្តុះបណ្តាលដល់គណ:កម្មការ | | | | | | | | | | | | | | | | | | |
| ៩. ផ្តល់អាហាររូបករណ៍ដល់កុមារកំព្រា | | | | | | | | | | | | | | | | | | |
| ១០. ផ្តល់បង្គន់អនាម័យ | | | | | | | | | | | | | | | | | | |
| ១១. ផ្តល់របរបន្ថែម (ពូជសត្វ, ដំណាំ) | | | | | | | | | | | | | | | | | | |
| ១២. ផ្តល់បច្ចេកទេសចិញ្ចឹមសត្វ, ដំណាំ | | | | | | | | | | | | | | | | | | |
| ១៣. ឧបករណ៍ សម្ភារ:សំរាប់សហគមន៍ | | | | | | | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក

លោកនាយផ្នែករដ្ឋបាលជលផល

នាយសង្កាត់រដ្ឋបាលជលផល...

...ថ្ងៃទី...17...ខែ...10...ឆ្នាំ ២០០8

លេខ :...............

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**បានឃើញ**

មេឃុំ...

...ថ្ងៃទី...23...ខែ...10...ឆ្នាំ ២០០8

លេខ :...

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

...........ថ្ងៃទី...27...ខែ...11...ឆ្នាំ ២០០8

**នាយអធិការដ្ឋានរដ្ឋបាលជលផល...**

...ថ្ងៃទី...17...ខែ...10...ឆ្នាំ ២០០8

**ប្រធានគណ:កម្មការសហគមន៍នេសាទ**

លេខ :...02...

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល...

...........ថ្ងៃទី...21...ខែ...10...ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល...**